ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ

២-មេធាវី អ៊ុំ គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៊ុលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកន្ធូន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មានទួ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី យឹម វិសុទ្ធ

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហួរ

២៣-មេធាវី អ៊ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ : ០៤៧ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៦

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុង នៃដំណើរការការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី

## ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៨
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦។

## ស ម្រេ ច

ដាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុងនៃដំណើរការការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលបានទទួលការអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៩៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨

ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

# បទបញ្ជាផ្ទៃក្នុង
# នៃដំណើរការការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងកំណត់បែបបទនៃដំណើរការការងាររបស់ក្រុមប្រឹក្សាគណៈមេធាវី និង វិន័យការងាររបស់សមាជិកក្រុមប្រឹក្សាគណៈមេធាវី សំដៅពង្រឹងគុណភាព ប្រសិទ្ធភាពការងារ និងកិត្យានុភាពរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២.-**

វាក្យស័ព្ទនៃបទបញ្ជាផ្ទៃក្នុងនេះមានដូចតទៅ៖

- ក្រុមប្រឹក្សា សំដៅដល់ក្រុមប្រឹក្សាគណៈមេធាវី ។
- កិច្ចប្រជុំ សំដៅដល់កិច្ចប្រជុំនៃក្រុមប្រឹក្សាគណៈមេធាវី ។
- ប្រធាន សំដៅដល់ប្រធានគណៈមេធាវី ។
- សមាជិក សំដៅដល់សមាជិករបស់ក្រុមប្រឹក្សាគណៈមេធាវី ។

## ជំពូកទី ២
## កិច្ចប្រជុំនៃក្រុមប្រឹក្សាគណៈមេធាវី

**ប្រការ ៣.-**

កិច្ចប្រជុំនៃក្រុមប្រឹក្សាត្រូវធ្វើនៅទីស្នាក់ការនៃគណៈមេធាវី ឬ ទីកន្លែងផ្សេងទៀតតាមការកំណត់របស់ប្រធាន។ ក្រុមប្រឹក្សារួមប្រជុំតាមការផ្តួចផ្តើមគំនិតរបស់ប្រធាន ដែលជាអ្នករៀបចំរបៀបវារៈ។ សមាជិកចំនួន ១/៣ (មួយភាគបី) អាចស្នើសុំមកប្រធាន ដើម្បីពិនិត្យ និងសម្រេចកោះប្រជុំ។

**ប្រការ ៤.-**

លើកលែងតែមានកិច្ចការប្រញាប់ ប្រធានត្រូវកោះអញ្ជើញសមាជិកឱ្យបានយ៉ាងតិច ០៣ (បី) ថ្ងៃមុនថ្ងៃកំណត់ប្រជុំ ដោយភ្ជាប់ជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំ តាមគ្រប់មធ្យោបាយសមស្រប ។

**ប្រការ ៥.-**

កិច្ចប្រជុំត្រូវដឹកនាំដោយប្រធាន ។

**ប្រការ ៦.-**

កិច្ចប្រជុំអាចដំណើរទៅបាន លុះត្រាតែមានសមាជិកវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់។

**ប្រការ ៧.-**

ក្រុមប្រឹក្សាសម្រេចសេចក្តីតាមមតិភាគច្រើននៃសមាជិកវត្តមាន និងផ្ទេរសិទ្ធិ។

សមាជិកមួយរូប មានសិទ្ធិបោះឆ្នោតសម្រេចចំនួនមួយសំឡេង។

**ប្រការ ៨.-**

សមាជិកត្រូវចូលរួមកិច្ចប្រជុំឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**ប្រការ ៩.-**

សមាជិកដែលមានធុរៈមិនអាចចូលរួមក្នុងកិច្ចប្រជុំបាន ត្រូវជូនដំណឹងអំពីអវត្តមានរបស់ខ្លួនមកប្រធាន ក្នុងរយៈពេលសមស្រប តាមគ្រប់មធ្យោបាយសមស្រប។

សមាជិកដែលមានធុរៈអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនសមាជិកណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនក្នុងការបោះឆ្នោតសម្រេចលើបញ្ហានានានៅក្នុងកិច្ចប្រជុំ។

សមាជិកម្នាក់អាចទទួលការផ្ទេរសិទ្ធិបានតែមួយប៉ុណ្ណោះ។

**ប្រការ ១០.-**

ការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាអាចធ្វើឡើងតាមវិធីបោះឆ្នោតជាសម្ងាត់ ឬដោយលើកដៃ។

ការជ្រើសរើសយកវិធីណាមួយក្នុងការសម្រេចសេចក្តី ត្រូវមានការសម្រេចពីកិច្ចប្រជុំជាមុនដោយលើកដៃ។

**ប្រការ ១១.-**

មុននឹងចាប់ផ្តើមកិច្ចប្រជុំ ក្រុមប្រឹក្សាត្រូវសម្រេចអនុម័តលើរបៀបវារៈនៃកិច្ចប្រជុំជាមុនសិន។

**ប្រការ ១២.-**

សមាជិកអាចបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរីលើចំណុចនីមួយៗនៃរបៀបវារៈ ប៉ុន្តែមិនត្រូវនិយាយចាកប្រធានបទ វាយប្រហារបុគ្គល ឬធ្វើឱ្យខាតបង់ពេលវេលារបស់កិច្ចប្រជុំនោះទេ។

មុននឹងបញ្ចេញមតិយោបល់ សមាជិកត្រូវសុំការអនុញ្ញាតពីប្រធានជាមុនសិន។

ប្រធានមានសិទ្ធិព្រមានដោយផ្ទាល់មាត់ ឬហាមឃាត់ការបញ្ចេញមតិយោបល់របស់សមាជិកណាដែលនិយាយចាកប្រធានបទ ឬនិយាយវាយប្រហារបុគ្គល ឬនិយាយធ្វើឱ្យខាតបង់ពេលវេលា។

**ប្រការ ១៣.-**

រាល់មតិយោបល់ និងការពិភាក្សារបស់កិច្ចប្រជុំ ត្រូវរក្សាជាការសម្ងាត់។

រាល់ការទម្លាយការសម្ងាត់នៃពត៌មានទាំងអស់នេះត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

**ប្រការ ១៤.-**

ប្រធានចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំ និងលើលទ្ធផលនៃកិច្ចប្រជុំ ហើយបញ្ជូនទៅសមាជិក ក្នុងរយៈពេលសមស្រប និងតាមមធ្យោបាយសមស្រប។

## ជំពូកទី ៣

## លេខាកិច្ចប្រជុំ

**ប្រការ ១៥.-**

គ្រប់កិច្ចប្រជុំ ត្រូវមានលេខាអង្គប្រជុំម្នាក់ និងលេខាកត់ត្រាម្នាក់ដើម្បីជាជំនួយការ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំ ។

លេខាអង្គប្រជុំ និងលេខាកត់ត្រាត្រូវសម្រេចចាត់តាំងដោយក្រុមប្រឹក្សា តាមសំណើរបស់ប្រធាន ក្នុងចំណោមអគ្គលេខាធិការ អគ្គលេខាធិការរង និងតំណាងនាយកដ្ឋានរដ្ឋបាល នៃគណៈមេធាវី នៅក្នុងកិច្ចប្រជុំនីមួយៗ។

## ជំពូកទី ៤

## វិន័យការងាររបស់សមាជិក

**ប្រការ ១៦.-**

សមាជិកត្រូវប្រកាន់ខ្ជាប់នូវសីលធម៌វិជ្ជាជីវៈ ភាពថ្លៃថ្នូរ យកចិត្តទុកដាក់ក្នុងការបំពេញការងារ និងតួនាទីជាសមាជិក ព្រមទាំងបញ្ចេញសមត្ថភាព និងសកម្មភាពរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍គណៈមេធាវី។

**ប្រការ ១៧.-**

សមាជិកមិនត្រូវដើរចេញពីកិច្ចប្រជុំ ដោយគ្មានមូលហេតុ និងដោយគ្មានការជម្រាបជូនប្រធានអង្គប្រជុំឡើយ។

**ប្រការ ១៨.-**

សមាជិកត្រូវបំពេញតួនាទីរបស់ខ្លួនដោយមានការទទួលខុសត្រូវខ្ពស់ និងមិនត្រូវអនុវត្តសកម្មភាពណាដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិនាមរបស់គណៈមេធាវីឡើយ។

**ប្រការ ១៩.-**

សមាជិកត្រូវមានសាមគ្គីភាពគ្នា ចៀសវាងការរើសអើង និងការនិយាយវាយប្រហារគ្នាតាមគ្រប់រូបភាព។

## ជំពូកទី ៥

## ទណ្ឌកម្មវិន័យ

**ប្រការ ២០.-**

សមាជិកណាដែលបានប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនេះ ត្រូវទទួលទណ្ឌកម្មវិន័យដូចខាងក្រោម៖

- ការស្តីបន្ទោស ។
- ការព្រមានជាលាយលក្ខណ៍អក្សរ ។

ទណ្ឌកម្មវិន័យដែលត្រូវដាក់ចំពោះសមាជិកណាម្នាក់ ត្រូវសម្រេចដោយក្រុមប្រឹក្សា ។

## ជំពូកទី ៦

## ការកែប្រែបទបញ្ជាផ្ទៃក្នុង

**ប្រការ ២១.-**

បទបញ្ជាផ្ទៃក្នុងនេះ អាចត្រូវបានកែប្រែក្នុងករណីចាំបាច់ ដោយកិច្ចប្រជុំ តាមសំណើរបស់ប្រធាន ឬតាមសំណើរបស់សមាជិកចំនួនលើសពី ១/៣ (មួយភាគបី) ។

**មេធាវី.ប៊ុន_ហុន**

**ចម្លងជូន:**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-សមាជិកក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ